# ជម្មនុញ្ញសន្តិភាពសកល

## ដើម្បីមនុស្សជាតិ និងភពផែនដី




**សភាអន្តរជាតិ**

**ដើម្បីភាពអត់ឱន និងសន្តិភាព (IPTP)**

ភ្នំពេញ ២៥ វិច្ឆិកា ២០២៤

# ធម្មនុញ្ញសន្តិភាពសកល
# ដើម្បីមនុស្សជាតិ និងភពផែនដី

## អំពីធម្មនុញ្ញ

ធម្មនុញ្ញសន្តិភាពសកល ដែលតទៅនេះហៅថា ធម្មនុញ្ញសន្តិភាព គឺជាក្របខណ្ឌអន្តរជាតិមួយដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹងជាសកលនូវសាមគ្គីភាព និងភាពជាដៃគូអន្តរជាតិ ដើម្បីសន្តិភាព សុខដុមរមនា សេចក្ដីថ្លៃថ្នូរ និងវិបុលភាពសម្រាប់មនុស្សជាតិ។ ធម្មនុញ្ញសន្តិភាពនេះឈរលើគោលការណ៍ជាមូលដ្ឋានរួមមាន៖ ១) ឯកភាពគ្នាក្នុងភាពចម្រុះ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ភាពជាអ្នកជិតខាងល្អ មិត្តភាព ការមិនឈ្លានពាន និងមិនជ្រៀតជ្រែក ២) ការគោរពគ្នាទៅវិញទៅមក ការយោគយល់គ្នាទៅវិញទៅមក ការទុកចិត្តគ្នាទៅវិញទៅមក និងការផ្ដល់ផលប្រយោជន៍ទៅវិញទៅមក ដើម្បីសន្តិភាព និងវិបុលភាព (M4P2) ៣) ភាពអត់ឱន សេចក្ដីស្រឡាញ់ សមភាព តម្លាភាព និងយុត្តិធម៌ ៤) ការរួមរស់ជាមួយគ្នាដោយសន្តិភាព និងការដោះស្រាយជម្លោះដោយសន្តិភាពនិងភាពចម្រុះ និង ៥) វប្បធម៌នៃសន្តិភាព និងការសន្ទនា។ ស្របតាមគោលការណ៍ និងគោលបំណងនៃធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងគោលការណ៍នៃសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ជាសកលផ្សេងទៀត រួមមាន សេចក្ដីប្រកាសទីក្រុងបានដុង និងសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការ (TAC) នៅតំបន់អាស៊ីអាគ្នេយ៍ ធម្មនុញ្ញសន្តិភាពនេះពង្រឹងសន្តិភាពដើម្បីមនុស្សជាតិ និងភពផែនដី។

### បុព្វកថា

**យើងជាប្រជាជន**នៃប្រជាជាតិ និងអង្គភាពដែលស្រឡាញ់សន្តិភាព ដែលតទៅនេះហៅថា ភាគីទាំងអស់ ត្រូវបានរួបរួមដោយបំណងប្រាថ្នា និងឆន្ទៈរួម ដើម្បីរស់នៅក្នុងសន្តិភាព សុខដុមរមនា សេចក្ដីថ្លៃថ្នូរ និងវិបុលភាព

**ប្រកាន់ភ្ជាប់**នូវគោលបំណង និងគោលការណ៍នៃធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្ដីប្រកាសទីក្រុងបានឌុង សន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ និងសន្ធិសញ្ញា និងអនុសញ្ញាអន្តរជាតិដែលទទួលស្គាល់ជាសកលផ្សេងទៀតស្ដីពីសន្តិភាព

**បង្ហាញពី**បំណងប្រាថ្នារបស់យើង ក្នុងការក្លាយជាស្ថាប័នដ៏មានកិត្តិយស និងភាពថ្លៃថ្នូរមួយនៅក្នុងចំណោមប្រជាជាតិនានា ខិតខំថែរក្សាសន្តិភាព និងមនុស្សជាតិ និងធានាបានថាប្រជាជនទាំងអស់ក្នុងពិភពលោកមានសិទ្ធិរស់នៅដោយសន្តិភាព

**ប្តេជ្ញាចិត្ត**ក្នុងការលើកកម្ពស់តម្លៃនៃសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាសកល ស្វ័យសម្រេច និង ការទទួលខុសត្រូវក្នុងការលើកកម្ពស់សន្តិភាព ដើម្បីធានាថាប្រជាជាតិ និងប្រជាជនទាំងអស់អាចរស់នៅ ស្របតាមពនិយមន័យនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស រួមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និង វប្បធម៌ ព្រមទាំងសិទ្ធិជាពលរដ្ឋស៊ីវិល និងសិទ្ធិនយោបាយ

**គោរព**មូលដ្ឋាននៃសិទ្ធិមនុស្ស និងការមិនរើសអើង ដែលជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និង សន្តិភាព ដែលអនុញ្ញាតឱ្យបុគ្គល និងសហគមន៍អាចកសាងជីវិតដ៏ល្អពេញលេញ

**ប្តេជ្ញាចិត្ត**ក្នុងការលើកកម្ពស់សន្តិភាព ការអត់ឱន និងការអភិវឌ្ឍប្រកបដោយចីរភាពតាមរយៈការ ពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការពហុភាគី

**សន្យា**កសាងសហគមន៍ពិភពលោកប្រកបដោយសន្តិភាព និងវិបុលភាព ដោយផ្តោតលើការការពារ ភពផែនដីរបស់យើងជារួម និងបរិស្ថាន ការរួមរស់ជាមួយគ្នាក្នុងចំណោមប្រជាជាតិ ការដោះស្រាយ ភាពខុសគ្នាដោយសន្តិវិធី មនុស្សធម៌ មេត្តាធម៌ និងសេចក្តីសប្បុរស និង

**ទទួលស្គាល់**ធម្មនុញ្ញនេះ ជាក្របខណ្ឌស្ថាប័នមួយ ដែលត្រូវបានបង្កើតឡើងដើម្បីពង្រឹងសាមគ្គីភាព និងភាពជាដៃគូអន្តរជាតិ ដើម្បីសន្តិភាព សុខដុមរមនា សេចក្តីថ្លៃថ្នូរ និងវិបុលភាពសម្រាប់មនុស្សជាតិ។

បានឯកភាពដូចខាងក្រោម៖

## ជំពូកទី១៖ គោលបំណង និងគោលការណ៍

## ប្រការ ១៖ គោលបំណង

ធម្មនុញ្ញនេះមានគោលបំណងលើកកម្ពស់សន្តិភាព ភាពអត់ឱន ការផ្សះផ្សារ និងការអភិវឌ្ឍ ប្រកបដោយចីរភាព តាមរយៈការពង្រឹងកិច្ចសន្ទនា និងកិច្ចសហប្រតិបត្តិការពហុភាគី នៅក្នុង និម្មាបនកម្មនៃការកសាងសន្តិភាពជាសកលមួយ ដែលឈរលើស្មារតីនៃពហុភាគីនិយមរួម និងគោល ការណ៍ជាមូលដ្ឋាននៃសាមគ្គីភាព សន្តិភាព ច្បាប់អន្តរជាតិ ពាណិជ្ជកម្មសេរី និងតម្លាភាព ភាពជាអ្នក ជិតខាងល្អ មិត្តភាព ការពឹងពាក់គ្នាទៅវិញទៅមក សមភាព យុត្តិធម៌ ការជឿទុកចិត្តគ្នាទៅវិញទៅមក ភាពរុងរឿង និងការអភិវឌ្ឍទៅវិញទៅមក តម្លៃជាសកល និងការរួមរស់ដោយសន្តិភាព។

គោលបំណងនៃធម្មនុញ្ញសន្តិភាពនេះគឺ៖

១. ដើម្បីស្វែងរកសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍជាអចិន្ត្រៃយ៍ក្នុងចំណោមប្រជាជាតិ និងសហគមន៍ដោយផ្អែកលើពហុភាគីនិយមបើកចំហ និងបរិយាប័ន្ន ព្រមទាំងច្បាប់ និងបទដ្ឋានដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិសម្រាប់ការដោះស្រាយជម្លោះដោយសន្តិវិធី

២. ដើម្បីបញ្ចៀសជម្លោះ តាមរយៈការពង្រឹងច្បាប់ និងបទដ្ឋាន ការអត់ឱន និងការទូតដែលបង្ការទុកមុន

៣. ដើម្បីដោះស្រាយជម្លោះតាមរយៈមធ្យោបាយសន្តិវិធី រួមមានការដោះស្រាយតាមការទូត កិច្ចសន្ទនា ការសម្របសម្រួល កិច្ចសម្របសម្រួលល្អ និងផ្លូវច្បាប់

៤. ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងកសាងសន្តិភាពក្រោយជម្លោះ ក្នុងការទប់ស្កាត់ជម្លោះពីការកើតឡើងវិញតាមរយៈការកសាងសេដ្ឋកិច្ចសង្គម និងការលើកកម្ពស់យុត្តិធម៌អន្តរកាល

៥. ដើម្បីលើកកម្ពស់សន្តិសុខរបស់មនុស្ស ជាពិសេស សន្តិសុខទឹក ថាមពល និងស្បៀងអាហារក្នុងកម្រិតមូលដ្ឋានតាមរយៈការអភិវឌ្ឍបៃតង ការអភិរក្សធនធាន នវានុវត្តន៍បច្ចេកវិទ្យា និងវិទ្យាសាស្ត្រកសិកម្ម និងចំណីអាហារ

៦. ដើម្បីគៀងគរ និងបែងចែកធនធានដើម្បីដោះស្រាយវិបត្តិអាកាសធាតុសកល និងគាំទ្រកិច្ចខិតខំប្រឹងប្រែងជាសកល ដើម្បីសម្រេចនូវរបៀបវារៈឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិសម្រាប់ការអភិវឌ្ឍន៍ប្រកបដោយចីរភាព (UNSDGs) និងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនាពេលអនាគត

៧. ដើម្បីពង្រឹងស្ថាប័នសង្គមស៊ីវិល គ្រឹះស្ថានសិក្សា ស្ថាប័នស្រាវជ្រាវ ព្រមទាំងសុខុមាលភាពប្រជាជន ដែលមានសារៈសំខាន់សម្រាប់សន្តិភាពយូរអង្វែង

៨. ដើម្បីបង្កើតភាពជាដៃគូកាន់តែជិតស្និទ្ធ និងទូលំទូលាយបន្ថែមទៀតក្នុងចំណោមសភាទូទាំងពិភពលោក និងការជំរុញឱ្យមានការបង្កើតសភាសកល (UPA) នៅពេលក្រោយ ដែលជាវេទិកាសភាដ៏លេចធ្លោមួយ ដើម្បីបង្ហាញនូវបណ្ដាញនៃសភាពិភពលោកដែលល្អប្រសើរ ក្នុងការសហការជាមួយសមាជិក និងដៃគូរបស់ខ្លួនដើម្បីអនុវត្តបេសកកម្មធម្មនុញ្ញសន្តិភាព

៩. ដើម្បីលើកកម្ពស់សន្តិភាពប្រកបដោយចីរភាព ការផ្សះផ្សា និងភាពសុខដុមរមនាក្នុងចំណោមសាសនា វប្បធម៌ និងអរិយធម៌ តាមរយៈការសន្ទនា ការគោរព និងការអត់ឱនគ្នាទៅវិញទៅមក

១០. ដើម្បីលើកកម្ពស់ប្រព័ន្ធទំនាក់ទំនង និងប្រព័ន្ធផ្សព្វផ្សាយដែលគួរឱ្យទុកចិត្ត ដើម្បីសន្តិភាព ភាពអត់ឱន និងការអភិវឌ្ឍប្រកបដោយចីរភាព និង

១១. ដើម្បីទាក់ទងគ្រប់ភាគីទាំងអស់ ដើម្បីជំរុញបេសកកម្មដ៏ឧត្តមនេះ ដែលជាទំនួលខុសត្រូវរួមមួយសម្រាប់និរន្តរភាព និងវិបុលភាពរបស់អរិយធម៌មនុស្សជាតិ។

## ប្រការ ២៖ គោលការណ៍

ភាគីទាំងអស់ត្រូវប្រកាន់យកគោលការណ៍ជាមូលដ្ឋានដូចខាងក្រោម៖

១. សាមគ្គីភាពគ្នាក្នុងភាពចម្រុះ អធិបតេយ្យភាពជាតិ បូរណភាពទឹកដី ភាពជាអ្នកជិតខាងល្អ ការមិនឈ្លានពាន ការមិនជ្រៀតជ្រែក និងសហវិបុលភាព

២. ការគោរពគ្នា ការយោគយល់គ្នា ការទុកចិត្តគ្នា និងការផ្តល់ផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមកដើម្បីសន្តិភាព និងវិបុលភាព (M4P2)

៣. ភាពអត់ឱន សេចក្តីស្រលាញ់ សមភាព តម្លាភាព និងយុត្តិធម៌

៤. ការរួមរស់ជាមួយគ្នាដោយសន្តិភាព និងការដោះស្រាយជម្លោះដោយសន្តិវិធី និងភាពចម្រុះ

៥. វប្បធម៌សន្តិភាព និងការសន្ទនា។

## ជំពូកទី ២៖ វិស័យនានាក្នុងកិច្ចសហប្រតិបត្តិការ

ដោយការទុកចិត្តគ្នា និងមិនមានភាពភ័យខ្លាច ជាមួយនិងទំនុកចិត្ត និងសុច្ឆន្ទៈចំពោះគ្នាទៅវិញទៅមក ភាគីទាំងអស់នឹងអនុវត្តការអត់ឱន និងការរួមរស់ជាមួយគ្នាដោយសន្តិភាព ក្នុងនាមជាអ្នកជិតខាងល្អ និងអភិវឌ្ឍកិច្ចសហប្រតិបត្តិការជាមិត្តភាព ដើម្បីសន្តិភាពក្នុងវិស័យសំខាន់ៗដូចខាងក្រោម៖

### ប្រការ ៣៖ ការបញ្ចៀសជម្លោះ

ភាគីទាំងអស់ត្រូវ៖

- លើកកម្ពស់ការកាត់បន្ថយការគំរាមកំហែងនៃការប្រើប្រាស់កម្លាំង ឬការប្រើប្រាស់កម្លាំងប្រឆាំងនឹងបូរណភាពទឹកដី ឬឯករាជ្យភាពនយោបាយនៃរដ្ឋណាមួយ
- ជៀសវាងការចូលរួមក្នុងសកម្មភាពណាមួយដែលគំរាមកំហែងដល់សន្តិភាព និងស្ថិរភាពនយោបាយនៅរដ្ឋដទៃ តំបន់ និងពិភពលោក
- ខិតខំឱ្យអស់ពីលទ្ធភាព ទាំងក្នុងក្របខណ្ឌពហុភាគី ក្របខណ្ឌទ្វេភាគី និងឯកតោភាគី ដើម្បីទប់ស្កាត់ជម្លោះគ្រប់ទម្រង់កុំឱ្យកើតឡើង
- បន្តលើកកម្ពស់សន្តិភាពយូរអង្វែង មិត្តភាពជានិរន្តរ៍ និងកិច្ចសហប្រតិបត្តិការដែលផ្តល់ផលប្រយោជន៍ទៅវិញទៅមកក្នុងចំណោមប្រជាជាតិទាំងអស់ ដើម្បីបង្កើនស្ថិរភាព និងភាពធន់នៅកម្រិតពិភពលោក ថ្នាក់តំបន់ ថ្នាក់ជាតិ និងមូលដ្ឋាន
- សម្របសម្រួលដំណោះស្រាយនយោបាយគ្រប់ជ្រុងជ្រោយសម្រាប់ជម្លោះដែលមានស្រាប់ដោយផ្អែកលើច្បាប់ និងបទដ្ឋានអន្តរជាតិ និងតាមរយៈវិធីសាស្ត្រឈ្នះ-ឈ្នះ
- ដោះស្រាយវិវាទទាំងអស់ដោយសន្តិវិធី ដូចជាការចរចា ការផ្សះផ្សា មជ្ឈត្តកម្ម ឬការដោះស្រាយតាមផ្លូវតុលាការ ព្រមទាំងមធ្យោបាយសន្តិវិធីផ្សេងទៀតដែលបានព្រមព្រៀងដោយភាគីពាក់ព័ន្ធផ្ទាល់ ដោយអនុលោមតាមធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ច្បាប់អន្តរជាតិ និងបទដ្ឋាន និងការអនុវត្តដែលទទួលស្គាល់ជាសកលផ្សេងទៀត

- បញ្ចប់និទណ្ឌភាព និងលើកកម្ពស់ការទទួលខុសត្រូវចំពោះការរំលោភលើច្បាប់មនុស្សធម៌អន្តរជាតិ និងឧក្រិដ្ឋកម្មស្លូលដែលជាក្ដីកង្វល់អន្តរជាតិស្របតាមច្បាប់ជាតិ និងច្បាប់អន្តរជាតិដែលមានស្រាប់
- ជំរុញការរួមរស់ជាមួយគ្នាប្រកបដោយសន្តិភាព និងកិច្ចសហប្រតិបត្តិការប្រកបដោយប្រសិទ្ធភាពជាមួយប្រជាជាតិទាំងអស់លើគ្រប់វិស័យ ដែលលើកកម្ពស់សន្តិភាព សន្តិសុខ ស្ថិរភាព សេចក្ដីថ្លៃថ្នូររបស់មនុស្ស និងវឌ្ឍនភាពសង្គម
- រក្សាទំនាក់ទំនងទៀងទាត់ ការឆ្លើយឆ្លង និងការពិគ្រោះយោបល់ជាមួយគ្នាទៅវិញទៅមកលើបញ្ហាអន្តរជាតិ និងតំបន់ និង
- ជំរុញកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម និងភាពធន់នៃប្រជាជាតិទាំងឡាយ ដើម្បីសម្រេចបាននូវសហគមន៍មួយប្រកបដោយវិបុលភាព និងសន្តិភាពសម្រាប់ទាំងអស់គ្នា។

## ប្រការ ៤៖ ភាពជាអ្នកដឹកនាំសម្រាប់សន្តិភាព

ភាគីទាំងអស់ត្រូវ៖

- ខិតខំពង្រឹង និងជំរុញកិច្ចសហប្រតិបត្តិការបន្ថែមទៀត ដើម្បីបុព្វហេតុសន្តិភាព ភាពសុខដុមរមនា និងស្ថិរភាពក្នុងតំបន់ និងពិភពលោក
- ខិតខំលើកកម្ពស់ភាពជាអ្នកដឹកនាំសន្តិភាពក្នុងជួររដ្ឋាភិបាល អង្គការជំនឿ សង្គមស៊ីវិល និងវិស័យឯកជន ដើម្បីសម្រេចបាននូវកិច្ចសហប្រតិបត្តិការដ៏ជិតស្និទ្ធបំផុតឱ្យបានកាន់តែទូលំទូលាយ
- ជួយគ្នាទៅវិញទៅមកលើវិស័យអភិបាលកិច្ចល្អ ការចែករំលែកចំណេះដឹង ការកសាងសមត្ថភាព និងការបណ្ដុះបណ្ដាលសម្រាប់អ្នកដឹកនាំគ្រប់កម្រិតនាពេលបច្ចុប្បន្ន រួមទាំងអនាគតផងដែរ និង
- ផ្ដល់តម្លៃដល់អ្នកដឹកនាំគំរូចំពោះការខិតខំប្រឹងប្រែង និងសមិទ្ធផលសន្តិភាពរបស់ពួកគេជារៀងរាល់ឆ្នាំ។

## ប្រការ ៥៖ កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច

ភាគីទាំងអស់ត្រូវ៖

- ជំរុញការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចក្នុងចំណោមប្រជាជាតិទាំងអស់ ដោយឈរលើមូលដ្ឋាននៃផលប្រយោជន៍រួម កិច្ចសហប្រតិបត្តិការ និងការគោរពអធិបតេយ្យភាពជាតិ ដែលនាំមកនូវវិបុលភាព និងសុខមាលភាពរួម

- ពន្លឿន និងពង្រឹងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចដោយមានការគាំទ្រពីរដ្ឋាភិបាល និងថ្នាក់ដឹកនាំធុរកិច្ចឱ្យរីកចម្រើនដល់ប្រជាជាតិទាំងអស់ តាមរយៈការអនុម័តយុទ្ធសាស្ត្រសមស្រប សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងការជួយគ្នាទៅវិញទៅមក ដើម្បីពង្រឹងមូលដ្ឋានគ្រឹះសម្រាប់វិបុលភាព និងសន្តិភាពសហគមន៍ និង
- ខិតខំដើម្បីកសាងពហុភាគីនិយមពិតប្រាកដមួយ និងសកលភាវូបនីយកម្មដែលយុត្តិធម៌ សមធម៌ និងបរិយាប័ន្ន ដើម្បីកាត់បន្ថយឱនភាពសន្តិភាព ការអភិវឌ្ឍ សន្តិសុខ និងអភិបាលកិច្ច។

## ប្រការ ៦៖ យុត្តិធម៌អន្តរកាល

ភាគីទាំងអស់ត្រូវ៖

- ពង្រឹងភាពធន់នៃសង្គម និងសហគមន៍ក្រោយជម្លោះ និងការរួមរស់ដោយសន្តិភាពរវាងជនរងគ្រោះ សាក្សី និងជនល្មើស ក្នុងការលើកកម្ពស់សន្តិភាពយូរអង្វែងនៅកម្រិតថ្នាក់ជាតិ និងសហគមន៍
- ជំរុញឱ្យមានទាំងយុត្តិធម៌បែបទណ្ឌកិច្ច និងការស្តារឡើងវិញនៅក្នុងសង្គមក្រោយជម្លោះ បញ្ចៀសសង្គមក្រោយជម្លោះពីការកើតឡើងវិញនៃជម្លោះតាមរយៈការបញ្ចប់វប្បធម៌និទណ្ឌភាព និងធានាឱ្យមានសន្តិភាព និងការអភិវឌ្ឍប្រកបដោយបរិយាប័ន្ន
- កសាងមាគ៌ាជាប់លាប់ទៅកាន់សន្តិភាព រួមទាំងយន្តការស្វែងរកការពិត ការស្តារឡើងវិញនូវទំនុកចិត្តរបស់ពលរដ្ឋ និងការពង្រឹងសាមគ្គីភាពសង្គមតាមរយៈការចូលរួមរបស់ប្រជាពលរដ្ឋ និងការគាំទ្រពីអ្នកច្បាប់ និងមេធាវីនិង
- ធ្វើការដើម្បីកំណត់អត្តសញ្ញាណ និងដោះស្រាយភាពអយុត្តិធម៌សង្គម សេដ្ឋកិច្ច និងនយោបាយដែលមានស្រាប់ តាមរយៈកំណែទម្រង់ដែលផ្តោតលើប្រជាជន កិច្ចខិតខំសម្របសម្រួលដោយសន្តិវិធីក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់ ដើម្បីធានាបាននូវសន្តិភាពឈ្នះ-ឈ្នះ។

## ប្រការ ៧៖ សន្តិសុខស្បៀង ទឹក និងថាមពល

ភាគីទាំងអស់ត្រូវ៖

- ប្តេជ្ញាដោះស្រាយអសន្តិសុខស្បៀងក្នុងប្រទេស តំបន់ និងសកលលោក ហើយចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីធានាបាននូវសន្តិសុខស្បៀងសម្រាប់ប្រជាជនគ្រប់ពេលវេលា
- ប្រកាន់យកវិធីសាស្ត្ររួម និងពហុវិស័យ ដើម្បីសម្រេចបាននូវសន្តិសុខស្បៀង ដោយការពារប្រភពស្បៀងអាហារ និងប្រព័ន្ធអេកូឡូស៊ីចំណីអាហារ ដែលប្រើប្រាស់បច្ចេកវិទ្យាកសិកម្ម និងឧស្សាហកម្មប្រកបដោយនិរន្តរភាព និងការការពារបរិស្ថានក្នុងកសិដ្ឋានខ្នាតតូច និងខ្នាតធំ

- ជានាខ្សែសង្វាក់ផ្គត់ផ្គង់អាហារដោយរលូន ការដោះស្រាយវិបត្តិតម្លៃស្បៀងអាហារ
- លើកកម្ពស់ទំនាក់ទំនងសន្តិសុខទឹក ថាមពល ស្បៀង ដើម្បីលើកកម្ពស់ស្ថិរភាពប្រព័ន្ធស្បៀងអាហារ តាមរយៈការវិនិយោគបៃតង ការពង្រីកកសិកម្មដល់កសិករខ្នាតតូច និងការផ្តល់ការអប់រំ និងចំណេះដឹងស្តីពីការធ្វើពិពិធកម្មដំណាំ និងការគ្រប់គ្រងក្រោយការប្រមូលផល
- ជានានូវប្រព័ន្ធផលិតកម្មម្ហូបអាហារប្រកបដោយនិរន្តរភាព និងជំរុញការអនុវត្តកសិកម្មដែលមានភាពធន់ ដែលនឹងបង្កើនផលិតភាព និងផលិតកម្ម ជួយរក្សាប្រព័ន្ធអេកូឡូស៊ី និងពង្រឹងសមត្ថភាពក្នុងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ ដូចជាគ្រោះនៃអាកាសធាតុ គ្រោះរាំងស្ងួត ទឹកជំនន់ និងគ្រោះមហន្តរាយធម្មជាតិផ្សេងទៀត និង
- ផ្តល់ធនធានសម្រាប់ការស្រាវជ្រាវ និងការអភិវឌ្ឍបែបវិទ្យាសាស្ត្រ និងជំរុញការបង្កើតគោលនយោបាយផ្អែកលើភស្តុតាងសម្រាប់វិទ្យាសាស្ត្រកសិកម្ម និងអាហារ។

## ប្រការ ៨៖ សន្តិសុខអាកាសធាតុ និងបរិស្ថាន

ភាគីទាំងអស់ត្រូវ៖

- តាមដានឱ្យបានជិតដល់ និងបែងចែកធនធានដើម្បីដោះស្រាយវិបត្តិអាកាសធាតុសកល ដោយប្រើប្រាស់ វិធានការកាត់បន្ថយ និងសម្របខ្លួនតាមថ្នាក់ជាតិ តំបន់ និងអន្តរជាតិ
- អនុម័ត និងអនុវត្តគោនយោបាយ និងផែនការរួម ដើម្បីបរិយាប័ន្ន ប្រសិទ្ធិភាពធនធាន ការកាត់បន្ថយ និងការសម្របខ្លួនទៅនឹងការប្រែប្រួលអាកាសធាតុ និងភាពធន់ទៅនឹងគ្រោះមហន្តរាយ ស្របតាមគោលដៅអភិវឌ្ឍប្រកបដោយចីរភាពឆ្នាំ២០៣០ របស់អង្គការសហប្រជាជាតិ និងគោលដៅអភិវឌ្ឍនានានាពេលអនាគត
- ប្រកាន់ខ្ជាប់នូវសកម្មភាព និងគោលការណ៍នានា ដែលបានអនុម័តដោយអនុសញ្ញាក្របខណ្ឌអង្គការសហប្រជាជាតិ ស្តីពីការប្រែប្រួលអាកាសធាតុ រួមទាំងកិច្ចព្រមព្រៀងទីក្រុងប៉ារីសស្តីពីការប្រែប្រួលអាកាសធាតុដែលបានអនុម័តនៅក្នុងសន្និសីទស្តីពីការប្រែប្រួលអាកាសធាតុរបស់អង្គការសហប្រជាជាតិ (COP21) ក្នុងឆ្នាំ២០១៥ និងCOP29 ដែលទើបតែអនុម័តថ្មីៗនៅទីក្រុងបាគូឆ្នាំ២០២៤ និង
- ប្រមូលផ្តុំភាគីពាក់ព័ន្ធទាំងអស់ ដើម្បីបង្កើតក្រុមការងារជំនាញ ក្នុងការស្វែងរកអ្នកជំនាញ និងឧត្តមានុវត្តល្អៗ អំពីរបៀបដោះស្រាយ និងឆ្លើយតបទៅនឹងវិបត្តិអាកាសធាតុជាសមូហភាព។

## ប្រការ ៩៖ ស្ត្រី សន្តិភាព និងសន្តិសុខ

ភាគីទាំងអស់ត្រូវ៖

- ខិតខំសហការក្នុងក្របខណ្ឌពហុភាគី ទ្វេភាគី និងឯកតោភាគី ដើម្បីបង្កើនតួនាទីរបស់ស្ត្រីក្នុងការកសាងសន្តិភាព និងរក្សាសន្តិសុខនៅក្នុងសង្គមរៀងៗខ្លួន និងជុំវិញពិភពលោក
- ប្តេជ្ញាជំរុញយ៉ាងសកម្មក្នុងការលើកកម្ពស់សមភាពយេនឌ័រនៅទូទាំងពិភពលោក និងផ្តល់សិទ្ធិអំណាចដល់ស្ត្រីនៅគ្រប់ស្រទាប់សង្គម រួមទាំងផ្នែកវប្បធម៌ សង្គម នយោបាយ សុខភាព សេដ្ឋកិច្ច និងផ្នែកសំខាន់ៗនានាផ្សេងទៀត ដោយគោរពបាននូវជំនឿ អត្តសញ្ញាណ និងអរិយធម៌
- ផ្តល់ជូននូវកម្មវិធីពង្រឹងសមត្ថភាព និងការការពារផ្នែកច្បាប់ និងជំនួយដល់ស្ត្រី ដែលប្រឈមនឹងអំពើហិង្សា និងការលើសអើងលើស្ត្រីនៅក្នុងសហគមន៍របស់ពួកគេរៀងៗខ្លួន និង
- ខិតខំលើកកម្ពស់ និងបង្កើនការយល់ដឹងជាសាធារណៈ អំពីរបៀបវារៈស្ត្រី សន្តិភាព និងសន្តិសុខ (WPS) នៅកម្រិតជាតិ តំបន់ និងអន្តរជាតិ ដោយប្រើប្រាស់ធនធានតាមភាពជាក់ស្តែង។

## ប្រការ ១០៖ ការអប់រំ និងយុវជន

ភាគីទាំងអស់ត្រូវ៖

- ខិតខំកសាងបណ្តាញអន្តរជាតិមួយសម្រាប់ការកសាងសន្តិភាព តាមរយៈការអប់រំ ការលើកកម្ពស់ការយល់ដឹង និងការកសាងសមត្ថភាពមនុស្ស និងស្ថាប័នស្តីពីសន្តិភាព
- ជំរុញសន្តិភាពពិភពលោក ដោយលើកកម្ពស់យុវជនឱ្យក្លាយជាអ្នកដឹកនាំសន្តិភាព និងពលរដ្ឋពិភពលោក តាមរយៈការពង្រឹងជំនាញភាពជាអ្នកដឹកនាំ និងសមត្ថភាពរបស់ពួកគេ
- លើកកម្ពស់ទំនួលខុសត្រូវ និងសេចក្តីប្រាថ្នារបស់យុវជន និងក្រុមយុវជនសម្រាប់ការចូលរួមកាន់តែច្រើនក្នុងការសម្រេចចិត្ត ដែលជាមធ្យោបាយដ៏មានប្រសិទ្ធភាពមួយក្នុងការអភិវឌ្ឍភាពជាអ្នកដឹកនាំសន្តិភាពដ៏ល្អមួយសម្រាប់អនាគត និង
- ខិតខំលើកកម្ពស់គុណតម្លៃគ្រួសារមានសុភមង្គល និងរបៀបរបបរស់នៅដើម្បីសន្តិភាព នៅក្នុងគ្រួសារ សហគមន៍ សង្គម និងប្រទេសជាតិ។

## ប្រការ ១១៖ វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

ភាគីទាំងអស់ត្រូវ៖

- ធ្វើការសហការគ្នា ដើម្បីទាញយកសក្តានុពលពេញលេញនៃបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) និងបច្ចេកវិទ្យាឌីជីថលសម្រាប់ការពង្រឹងសន្តិភាព តាមរយៈការជំរុញការតភ្ជាប់រវាងប្រជាជន និងប្រជាជននៅក្នុងសហគមន៍ជនជាតិ និងសាសនាផ្សេងៗ ប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត ព័ត៌មានមិនត្រឹមត្រូវ និងព័ត៌មានក្លែងក្លាយ ពង្រឹងតម្លាភាព និងគណនេយ្យ

ភាពជាសាធារណៈ កាត់បន្ថយគម្លាតឌីជីថល និងការលើកកម្ពស់សង្គមដែលមានភាពធន់ និងបរិយាបន្ន

- ប្រើប្រាស់វត្តមាន និងភាពជឿនលឿននៃវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ (STI) រួមទាំងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) និងបច្ចេកវិទ្យាឌីជីថល ហើយកាត់បន្ថយគម្លាតរវាងប្រជាជាតិ និង/ឬសង្គមនានា ដើម្បីលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាទំនើបប្រកបដោយតម្លាភាព និងបរិយាបន្ន និង
- លើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង (ICT) បច្ចេកវិទ្យាឌីជីថល និងបញ្ញាសិប្បនិម្មិត ដើម្បីជាប្រយោជន៍ដល់មនុស្សជាតិ។

## ប្រការ ១២៖ ភាពអត់ឱនផ្នែកសាសនា និងវប្បធម៌

ភាគីទាំងអស់ត្រូវ៖

- លើកកម្ពស់ការតភ្ជាប់វប្បធម៌ និងកិច្ចសន្ទនាអន្តរជំនឿ ដើម្បីបង្កើនសាមគ្គីភាពអន្តរជាតិ និងឯកភាពជាតិក្នុងភាពចម្រុះ
- លើកកម្ពស់ការយល់ដឹងអន្តរវប្បធម៌ និងការកសាងការជឿទុកចិត្ត តាមរយៈការប្រាស្រ័យទាក់ទងប្រជាជន និងប្រជាជន និងការចែករំលែកចំណេះដឹង និង
- ជំរុញឱ្យមានការបង្កើតក្រុមប្រឹក្សារួបរួមអន្តរជំនឿ (IUC) នៅអង្គការសហប្រជាជាតិ ក៏ដូចជានៅថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន ដើម្បីផ្តល់យន្តការសម្រាប់កិច្ចសន្ទនាទល់មុខ និងកសាងប្រព័ន្ធទូលំទូលាយនៃអ្នកកសាងសន្តិភាពអន្តរសាសនា ដែលអាចបម្រើការងារនៅក្នុងយន្តការទាំងអស់នេះបាន។

## ប្រការ ១៣៖ សុចរិតភាពនៃប្រព័ន្ធផ្សព្វផ្សាយ និងព័ត៌មាន

ភាគីទាំងអស់ត្រូវ៖

- លើកកម្ពស់ប្រព័ន្ធសារព័ត៌មានដែលទុកចិត្ត និងមានការទទួលខុសត្រូវ ដែលជាសសរស្តម្ភគ្រឹះនៃលទ្ធិប្រជាធិបតេយ្យ ដែលមានសមត្ថភាពផ្តល់ព័ត៌មាន អប់រំ និងការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការនយោបាយ និងការសម្រេចចិត្ត
- ការពារ និងលើកកម្ពស់សេរីភាពនៃការបញ្ចេញមតិ និងសារព័ត៌មាន ក៏ដូចជាការពារអ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយប្រឆាំងនឹងការគំរាមកំហែង ការបំភិតបំភ័យ និង/ឬអំពើហិង្សាស្របតាមច្បាប់ដែលមានស្រាប់

- លើកកម្ពស់សុចរិតភាពនៃព័ត៌មាន និងដោះស្រាយបញ្ហាប្រឈមជុំវិញបដិវត្តន៍ឌីជីថល និងបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង រួមទាំងការការពារឯកជនភាព សន្តិសុខតាមអ៊ីនធឺណិត និងការប្រយុទ្ធប្រឆាំងនឹងព័ត៌មានមិនពិត និងការបន្លំគ្រប់ទម្រង់ និង
- លើកកម្ពស់ការបង្កើតដំណោះស្រាយដែលមានលក្ខណៈជាក់ស្តែង ដើម្បីដោះស្រាយបញ្ហាប្រឈម និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង និងបច្ចេកវិទ្យាឌីជីថលដែលមានលក្ខណៈសមធម៌ និងបរិយាប័ន្ន។

## ជំពូកទី ៣៖ សមាជិកភាព និងទំនួលខុសត្រូវ

### ប្រការ ១៤

សមាជិកភាពនៃធម្មនុញ្ញសន្តិភាពគឺបើកចំហសម្រាប់រដ្ឋ និងអង្គភាពទាំងអស់។ រដ្ឋសំដៅទៅលើរដ្ឋាភិបាល សភា និងអង្គការអន្តររដ្ឋាភិបាល។ អង្គភាពសំដៅលើអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ អង្គការឯកជនអន្តរជាតិ និងអង្គការសង្គមស៊ីវិល។ ដំណើរនៃការជ្រើសរើសសមាជិកភាពនឹងត្រូវពិនិត្យនិងអនុម័តដោយស្ថាប័ន ដែលទទួលបានការទុកចិត្តរបស់ធម្មនុញ្ញសន្តិភាព។

### ប្រការ ១៥

ភាគីទាំងអស់ត្រូវអនុវត្តភារកិច្ច និងការទទួលខុសត្រូវរបស់ខ្លួនក្រោមធម្មនុញ្ញសន្តិភាព ដែលនឹងត្រូវគ្រប់គ្រងដោយសំណុំនៃវិធាន និងគោលការណ៍ណែនាំនានា។

### ប្រការ ១៦

ភាគីទាំងអស់ត្រូវប្រកាន់ខ្ជាប់នូវគោលបំណង និងគោលការណ៍នៃធម្មនុញ្ញសន្តិភាព និងចាត់វិធានការចាំបាច់ទាំងអស់ ដើម្បីសម្រេចបាននូវគោលបំណងរួម។

## ជំពូកទី ៤៖ បទប្បញ្ញត្តិផ្សេងៗ

### ប្រការ ១៧

សម្រាប់ការងារដំណើរការ និងប្រតិបត្តិការនៃធម្មនុញ្ញសន្តិភាពនេះ ភាគីទាំងអស់នឹងពិភាក្សាបន្ថែមទៀតអំពីការបង្កើតយន្តការធ្វើការដើម្បីបម្រើឱ្យគោលបំណងនៃធម្មនុញ្ញសន្តិភាពនេះ។

### ប្រការ ១៨

សម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃធម្មនុញ្ញសន្តិភាព ភាគីទាំងអស់ត្រូវបង្កើតរចនាសម្ព័ន្ធអភិបាលកិច្ចប្រកបដោយបរិយាបន្ន ភាពធន់ និងផ្តោតលើអនាគត ដើម្បីរៀបចំ សម្របសម្រួល និង

ផ្តល់សិទ្ធិអំណាចដល់ភាគីនានាក្នុងការអនុវត្តតួនាទី និងការទទួលខុសត្រូវរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងលទ្ធផលល្អ។

## ប្រការ ១៩

ភាគីទាំងអស់ត្រូវពិចារណាបង្កើតមូលនិធិកសាងសន្តិភាព (PBF) ដើម្បីប្រមូលហិរញ្ញប្បទាន និងធនធានឱ្យបានគ្រប់គ្រាន់ និងមាននិរន្តរភាព ដើម្បីអនុវត្តគម្រោង និងកម្មវិធីសន្តិភាព។ ភាគីទាំងអស់ត្រូវសហការជាមួយគណៈកម្មការកសាងសន្តិភាពរបស់អង្គការសហប្រជាជាតិ និងមូលនិធិ ឬអង្គការសន្តិភាពផ្សេងទៀត។

## ប្រការ ២០

បានអនុម័ត និងប្រកាសនៅទីក្រុងភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា នៅសម័យប្រជុំពេញអង្គលើកទី ១១ នៃសភាអន្តរជាតិដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៤ ជាភាសាអង់គ្លេសដែលជាច្បាប់ដើម។

ជម្ពូញេសន្តិភាពសកល៖
ដើម្បីមនុស្សជាតិ និងភពផែនដី

**UNIVERSAL PEACE CHARTER**
FOR PEOPLE AND THE PLANET

UPC

MMXXIV